**WWF-Cambodia**

21, Street 322,
BoeungKeng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.wwf.org.kh
www.panda.org/greatermekong
wwfcambodia@wwf.org.kh

WWF *for a living planet*®

| សេចក្តីប្រកាសព័ត៌មាន | សម្រាប់ចេញផ្សាយបន្ទាន់ |
| --- | --- |

# សេចក្តីថ្លែងការរបស់អង្គការ WWF ក្នុងការគាំទ្ររដ្ឋាភិបាលចិន ចំពោះការហាមឃាត់ជាបណ្តោះអាសន្នលើការជួញដូរសត្វព្រៃ ដែលត្រូវបានគេសង្ស័យថាជាមូលហេតុនៃការឆ្លងវីរុស កូរ៉ូណា

យើងខ្ញុំពិតជាមានសេចក្តីក្រៀមក្រំណាស់ចំពោះការបាត់បង់ជីវិតមនុស្សដោយសារការផ្ទុះឡើងនូវ វីរុសកូរ៉ូណា ហើយយើងខ្ញុំសូមចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារដែលបានបាត់បង់សមាជិកជាទីស្រលាញ់ និងជនរងគ្រោះដោយការឆ្លងជំងឺនេះ។ ក្នុងពេលថ្មីៗនេះ រដ្ឋបាលជាតិព្រៃឈើ នៃប្រទេសចិន (NFGA) បានអនុវត្តវិធានការមួយចំនួនក្នុងការគ្រប់គ្រង និងបង្ការការឆ្លងរាលដាលនៃវីរុសនេះ។ ហើយយើងខ្ញុំសូមស្វាគមន៍ចំពោះសេចក្តីប្រកាសរបស់ NFGA និងនាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធនានាក្នុងប្រទេសចិន ក្នុងការដាក់ចេញនូវការហាមឃាត់យ៉ាងតឹងរឹងចំពោះការជួញដូរសត្វព្រៃគ្រប់ប្រភេទ ព្រមទាំងធ្វើការត្រួតពិនិត្យលិខិតអនុញ្ញាតផ្សេងៗតាមទីកន្លែងប្រើប្រាស់ ចិញ្ចឹម និងបង្កាត់ពូជសត្វព្រៃនានា។ សេចក្តីសម្រេចរបស់ប្រទេសចិនក្នុងការហាមឃាត់ជាបណ្តោះអាសន្នលើការជួញដូរសត្វព្រៃនេះ បញ្ជាក់យ៉ាងច្បាស់ពីតម្រូវការលើកកម្ពស់ចំណេះដឹងសាធារណៈជនឱ្យបានល្អប្រសើរជាងមុនស្តីអំពីហានិភ័យនានាចំពោះសុខភាពមនុស្សដែលបណ្តាលមកពីការជួញដូរសត្វព្រៃគ្មានការត្រួតពិនិត្យ និងខុសច្បាប់ ព្រមទាំងលើកកម្ពស់ការយល់ដឹងពីហេតុប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃការជួញដូរទៅលើចំនួនសត្វព្រៃ និងជីវៈចម្រុះជាសកលលោក។

យើងខ្ញុំសូមកោតសរសើរចំពោះចំណាត់ការយ៉ាងរហ័សរបស់ភ្នាក់ងារពង្រឹងច្បាប់គ្រប់ជាន់ថ្នាក់របស់ប្រទេសចិនក្នុងការបិទទីផ្សារលក់សត្វព្រៃ ភ្លាមក្រោយពេលការផ្ទុះឡើងនូវ វីរុសកូរ៉ូណា ថ្មីនេះ ដែលត្រូវបានសង្ស័យថាមានប្រភពពីក្រុង វូហាន (Wuhan) ក៏ដូចជាកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្ក្រាបការជួញដូរសត្វព្រៃខុសច្បាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ខណៈដែលការបិទទីផ្សារលក់សត្វព្រៃជាវិធានការមួយប្រសើរ ការដាក់ចេញនូវបម្រាមតែមួយមុខនោះមិនអាចបញ្ឈប់ការជួញដូរសត្វព្រៃខុសច្បាប់បានទេ ដរាបណាតម្រូវការសត្វព្រៃនៅតែមាន។ ករណីហានិភ័យលើសុខភាពមនុស្សដែលកំពុងកើតឡើងនេះ ជាការពញ្ញាក់ស្មារតីក្នុងការទាមទារឲ្យមានការបញ្ឈប់ការប្រើប្រាស់ដោយគ្មាននិរន្តរភាពនូវសត្វព្រៃ និងផលិតផល

សត្វព្រៃដែលកំពុងទទួលរងគ្រោះ ដោយការយកសត្វព្រៃមកធ្វើជាសត្វចិញ្ចឹម យកមកធ្វើជាអាហារទទួលទាន និងយកមកធ្វើជាឱសថនានា។

អង្គការ WWF សូមជម្រុញរដ្ឋាភិបាលចិន ឱ្យបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកាត់បន្ថយតម្រូវការនៃសត្វព្រៃ បន្តលើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈ និងសហការជាមួយរដ្ឋាភិបាល ស្ថាប័នអភិរក្សអន្តរជាតិ វិស័យឯកជន និងបណ្តាសហគមន៍មូលដ្ឋាន ក្នុងការបញ្ឈប់ការជួញដូរសត្វព្រៃខុសច្បាប់។ អង្គការ WWF ត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការតាមដានការជួញដូរសត្វព្រៃខុសច្បាប់ និងជួយគាំទ្រការកសាងសមត្ថភាពសម្រាប់ការងារពង្រឹងច្បាប់ ដើម្បីជួយដល់វិធានការនៃការបិទទីផ្សារសត្វព្រៃប្រកបដោយប្រសិទ្ធភាព។

---

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

Elizabeth Davis
202-495-4415
elizabeth.davis@wwfus.org

លោក ទេព អស្នារិទ្ធ
ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាន នៃអង្គការ WWF-កម្ពុជា
ទូរស័ព្ទលេខ៖ ០១២ ៩៥៧ ៩១៩
អ៊ីម៉ែល៖ asnarith.tep@wwf.org.kh

អំពីអង្គការ WWF-កម្ពុជា៖

អង្គការ WWF ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៨ ។ បេសកកម្មរបស់អង្គការ WWF គឺធានាឱ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF-កម្ពុជា នឹងជម្រុញឱ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

សម្រាប់ព័ត៌មានលំអិតសូមចូលទៅកាន់គេហទំព័ររបស់អង្គការ WWF-កម្ពុជា wwf.org.kh